**សូមគោរពជូន**

**-លោកជំទាវរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**-ឯកឧត្តមអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

**ជំរាប**

## ធនាគារពិភពលោក៖ ការធ្វើចំណាកស្រុក ជានិន្នាការវិជ្ជមាន

http://kleykley.sabay.com.kh/article/ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១៧ ម៉ោង 15:30

ការធ្វើចំណាកស្រុកទៅរកការងារធ្វើនៅទីក្រុង និងនៅក្រៅប្រទេស ជានិន្នាការវិជ្ជមានសម្រាប់គាំទ្រដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ នេះបើយោងតាមអ្នកសេដ្ឋវិទូជាន់ខ្ពស់ធនាគារពិភពលោក Miguel Eduardo Sanchez Martin។ លោក Miguel Eduardo Sanchez Martin បានបញ្ជាក់ថា "ប្រសិនបើប្រជាជនកម្ពុជាធ្វើចំណាកស្រុកទៅប្រទេសថៃ ពួកគេអាចទទួលបានជំនាញ ហើយត្រឡប់មកវិញជាមួយនឹងជំនាញទាំងនោះ។ ពួកគេប្រហែលជាអាចបើកអាជីវកម្ម ឬអាចធ្វើអ្វីផ្សេងទៀតនៅកម្ពុជា ដែលវាជាភាពវិជ្ជមាន"។ លោកបន្តទៀតថា ការធ្វើចំណាកស្រុកពីជនបទទៅកាន់ទីក្រុងដែលមានឱកាសការងារជាច្រើនក្នុងវិស័យផលិតកម្ម និងទេសចរណ៍ ក៏អាចជា "និន្នាការវិជ្ជមាន" ផងដែរ ហើយជាមូលដ្ឋានគាំទ្រដល់កំណើនសេដ្ឋកិច្ចនាពេលអនាគត។

ការសិក្សាថ្មីមួយបានរកឃើញថា គ្រួសារខ្មែរដែលបានទទួលការផ្ញើប្រាក់ពីចំណាកស្រុកក្នុងប្រទេស និងក្រៅប្រទេស អាចជួយកាត់បន្ថយអត្រាភាពក្រីក្រពី ៣ ទៅ ៧ ភាគរយពិន្ទុ៕

## រដ្ឋាភិបាលបញ្ចប់ការស៊ើបអង្កេតលើអង្គការមិនមែនរដ្ឋាភិបាលមួយដែលលោក ហ៊ុន សែន បញ្ជាឱ្យបិទ

http://www.cambodiadailykhmer.com/ ដោយ ផាន់ ស៊ូមី | ថ្ងៃសុក្រ ទី 18 ខែសីហា ឆ្នាំ2017

មន្ត្រីក្រសួងមហាផ្ទៃម្នាក់បាននិយាយកាលពីម្សិលមិញថា អាជ្ញាធរបានបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួនលើអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរផ្លូវភេទមួយ ដែលលោកនាយករដ្ឋមន្ត្រីបានបញ្ជាឱ្យបិទកាលពីដើមខែនេះ ចំពោះអ្វីដែលលោកហៅថាជាការប្រមាថ "ដែលមិនអាចអត់ឱនឱ្យបាន"ហើយអង្គការនេះបានធ្វើការសុំទោសប្រសិនបើព័ត៌មាននេះបង្កឱ្យមានការអាក់អន់ចិត្តនោះ។

កាលពីថ្ងៃទី១ ខែសីហា លោកនាយករដ្ឋមន្ត្រីបានដាក់បញ្ជាឱ្យពិនិត្យមើលអង្គការមេត្រីអន្តរជាតិ (AIM) ហើយបិទចោលភ្លាមៗ ជុំវិញអត្ថបទព័ត៌មានកាលពីពេលថ្មីៗរបស់បណ្តាញសារព័ត៌មាន CNN នេះដែលលោកបានចោទចំពោះការអះអាងដែលថា តំបន់ស្វាយប៉ាកដែលស្ថិតក្នុងរាជធានីភ្នំពេញធ្លាប់ជាកន្លែងមានឈ្មោះមិនល្អសម្រាប់ពេស្យាចារកុមារនោះ នៅតែជាកន្លែងនៃការជួញដូរផ្លូវភេទកុមារមិនទាន់គ្រប់អាយុដដែល។ រដ្ឋាភិបាលក៏បានរិះគន់របាយការណ៍ព័ត៌មាននេះផងដែរដែលបានបង្ហាញពីការងាររបស់អង្គការ AIM នៅក្នុងតំបន់ស្វាយប៉ាកចំពោះការអះអាងដែលថា ស្ត្រីជាម្តាយដែលលក់កូនរបស់ខ្លួនឱ្យបម្រើផ្លូវភេទជាជនជាតិកម្ពុជា មិនមែនជាជនជាតិ

វៀតណាម។ លោក ហ៊ុន សែន បានមានប្រសាសន៍នៅពេលនោះថា "នេះជាការប្រមាថដ៏ធ្ងន់ធ្ងរ"។លោកបន្ថែមថា "ដោយតម្លៃណាក៏ដោយ អង្គការមួយនេះត្រូវចាកចេញពីកម្ពុជា មិនអាចឱ្យនៅបានទៀតទេ"។

បើទោះជាមានការគំរាមបែបនេះក្តី ក៏អង្គការ AIM បានបន្តប្រតិបត្តិការខណៈស្ថិតក្រោមការស៊ើបអង្កេតចំពោះព័ត៌មានដែលខ្លួនបានផ្តល់ ឬមិនបានផ្តល់ដល់បណ្តាញសារព័ត៌មាន CNN សម្រាប់ការធ្វើសេចក្តីរាយការណ៍របស់ខ្លួន។

កាលពីម្សិលមិញ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃមានប្រសាសន៍ថា ការស៊ើបអង្កេតបានបញ្ចប់ហើយ។ លោកស្រីបានថ្លែងថា "ក្រសួងមហាផ្ទៃកំពុងតែស្វះស្វែងរកព័ត៌មានដើម្បីធ្វើការវាយតម្លៃទៅលើអង្គការ AIM អំពីគុណសម្បត្តិ និងចំណុចខ្វះខាត ដើម្បីទាញជាការសន្និដ្ឋានចុងក្រោយ តើអង្គការនេះអាចនឹងត្រូវបន្តសកម្មភាពទៀតឬមួយក៏យ៉ាងណា"។ លោកស្រី ជូ ប៊ុនអេង ដែលក៏ជាអនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សដែរនោះ មានប្រសាសន៍ថា អង្គការ AIM បានធ្វើ "កំហុស" ប៉ុន្តែបានបដិសេធមិននិយាយថាតើកំហុសនោះជាអ្វីឡើយ។ លោកស្រីបានបន្ថែមថា នៅក្នុងលិខិតមួយ អង្គការមិនមែនរដ្ឋាភិបាលនេះបាន "សុំទោសប្រសិនបើអ្វីដែលខ្លួនបានធ្វើនោះ ប៉ះពាល់ដល់ស្ត្រីកម្ពុជា ឬពលរដ្ឋកម្ពុជា"។ រដ្ឋលេខាធិការរូបនេះបានមានប្រសាសន៍ថា ក្រសួងកំពុងរៀបចំរបាយការណ៍ស្តីពីលទ្ធផលដែលខ្លួនបានរកឃើញដាក់ជូនលោកនាយករដ្ឋមន្ត្រីដែលមានសិទ្ធិសម្រេចចុងក្រោយថាតើអង្គការមិនមែនរដ្ឋាភិបាលនេះគួរនៅបន្តបើក ឬក៏យ៉ាងណានោះ ប៉ុន្តែលោកស្រីបានបដិសេធមិននិយាយថា របាយការណ៍នេះអាចត្រូវបានបញ្ចប់នៅពេលណានោះឡើយ។

និយាយពី CNN លោកស្រីមានប្រសាសន៍ថា ការសម្រេចរបស់បណ្តាញសារព័ត៌មានអាមេរិកនេះក្នុងការកែសម្រួលចំណងជើងនៅក្នុងអត្ថបទរបស់ខ្លួននោះ គឺជាការទទួលស្គាល់កំហុសរបស់ខ្លួន។ លោកស្រីបានថ្លែងថា អង្គការ AIM បានសុំធ្វើការកែសម្រួល។ ពីដំបូង បណ្តាញសារព័ត៌មានCNN បានចុះផ្សាយអត្ថបទមួយដែលមានចំណងជើងថា ជីវិតក្រោយការជួញដូរៈ ក្មេងស្រីកម្ពុជាត្រូវបានម្តាយពួកគេលក់ដើម្បីបម្រើផ្លូវភេទ" (Life after trafficking: The cambodian girls sold for sex by their mothers)"។ តែក្រោយមក ពាក្យ "Cambodian" ត្រូវបានដកចេញ។ នៅក្នុងសេចក្តីកែតម្រូវដែលបានចុះផ្សាយនោះ បណ្តាញសារព័ត៌មាននេះបានលើកឡើងថា ខ្លួនបានធ្វើការកែសម្រួល "ដើម្បីឆ្លុះបញ្ចាំងឱ្យកាន់តែត្រឹមត្រូវបន្ថែមទៀតអំពីខ្លឹមសារព័ត៌មាននោះ ដែលសំដៅដល់ក្មេងស្រីដើមកំណើតវៀតណាម ដែលជាជនរងគ្រោះនៃការជួញដូរផ្លូវភេទក្នុងប្រទេសកម្ពុជា"។

អង្គការ AIM បានបដិសេធចំពោះសំណើជាច្រើនសុំការបំភ្លឺ ហើយមិនអាចទាក់ទងបានកាលពីម្សិលមិញ។ កាលពីចុងខែកក្កដា ប៉ុន្មានថ្ងៃប៉ុណ្ណោះបន្ទាប់ពីរដ្ឋាភិបាលបានប្រកាសពីការស៊ើបអង្កេត បណ្តាញសារព័ត៌មាន CNN បានលើកឡើងថា ខ្លួនគាំទ្រសេចក្តីការណ៍ព័ត៌មានរបស់ខ្លួន៕ *សារុន (រាយការណ៍បន្ថែមដោយ Zsombor Peter)*

## **កម្ពុជា-ថៃ**

## **ទីតាំងត្រួតសញ្ញាតិជូនពលករខ្មែរនៅមិនទាន់បើកដំណើរការនៅឡើយទេនៅពេលនេះ**

http://pheaktraprak.com/archives/ โดย เพียะตรา ประ  สิงหาคม សីហា 17, 2017

កាលពីថ្ងៃព្រហស្បតិ៍ ទី17 ខែសីហា ឆ្នាំ2017លោករដ្ឋមន្ត្រីក្រសួងការងារថៃ បានមានប្រសាសន៍ប្រាប់អ្នកយកព័ត៌មាន នៅក្នុងកិច្ចប្រជុំរបស់ក្រសួងការងារថៃ លើកទី34 នៅខេត្តឧដនថានី លោកAnantachai Uthaiwattana រដ្ឋមន្ត្រីក្រសួងការងារថៃ បានលើកឡើងថា ចំពោះបងប្អូនពលករខ្មែរ ដែលធ្វើការសម្ភាសន៍ជាប់ហើយរង់ចាំត្រួតសញ្ញាតិនិងធ្វើប៉ាស្ព័រការងារ នោះនៅពេលនេះ ការិយាល័យត្រួតសញ្ញាតិបានកំណត់ទីតាំងត្រួតសញ្ញាតិច្បាស់លាស់ហើយ។ ទីតាំងទី1 ស្ថិតនៅក្នុងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ទីតាំង2 ស្ថិតនៅក្នុងហាងទំនិញOTOP ខេត្តរះយ៉ង ទីតាំង3 ស្ថិតនៅក្នុងផ្សារណាត់ ខេត្តសង់ខ្លា។ ក៏ប៉ុន្តែទីតាំងទាំងបីកន្លែងនៅមិនទាន់កំណត់ថ្ងៃបើកអោយត្រួតសញ្ញាតិជាផ្លូវការនោះទេ ដោយសារតែភ្នាក់ងារចុះត្រួតសញ្ញាតិកំពុងធ្វើការដឹកជញ្ជូនឧបករណ៍ទៅកាន់ទីតាំនីមួយៗ ហើយនៅក្រោយពេលដែលភ្នាក់ងារត្រួតសញ្ញាតិដំណើរការឧបករណ៍រួចរាល់នោះក្រសួងការងារថៃនិងធ្វើការប្រកាសជូនដំណឹងដល់និយោជកជាផ្លូវការម្តងទៀត។ ហេតុដូច្នេះបងប្អូនពលករខ្មែរដែលកំពុងរង់ចាំត្រួតពិនិត្យសញ្ញាតិសូមមេត្តារង់ចាំ។

ក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ